អេស៊ីលីដា
ACLEDA BANK

# របាយការណ៍
# ប្រចាំត្រីមាសទី៤
# ២០២៤

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ (គិតជាលានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៤ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
|---|---|---|---|
| ទ្រព្យសកម្មសរុប | ៤៣.៦០៦.១៧៣ | ៣៩.៨០៤.៤០៥ | ៣៧.១៨១.២៩៩ |
| បំណុលសរុប | ៣៧.៦០៨.២៥១ | ៣៤.១៥៨.៨៥០ | ៣១.៧៦០.៦៦០ |
| មូលធនសរុប | ៥.៩៩៧.៩២២ | ៥.៦៤៥.៥៥៥ | ៥.៤២០.៦៣៩ |
| **លទ្ធផលហិរញ្ញវត្ថុ (គិតជាលានរៀល)** | **ត្រីមាសទី៤ ឆ្នាំ២០២៤** | **ត្រីមាសទី៤ ឆ្នាំ២០២៣** | **ត្រីមាសទី៤ ឆ្នាំ២០២២** |
| ចំណូលសរុប | ៨៩៧.០៧១ | ៨៧៤.១០២ | ៨០៤.១៥៨ |
| ចំណេញ/(ខាត) មុនបង់ពន្ធ | ២៤៨.២១៩ | ១៨៦.១០៧ | ២៥០.៨៥១ |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ | ១៩២.៦៩២ | ១៥០.៦១២ | ២០១.៤០២ |
| លទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ | ១៦៦.៤៦០ | ៩១.៥០៩ | ១៩៤.០៣១ |
| **អនុបាតហិរញ្ញវត្ថុ (%)** | **ត្រីមាសទី៤ ឆ្នាំ២០២៤** | **ឆ្នាំ២០២៣** | **ឆ្នាំ២០២២** |
| អនុបាតសាធនភាព | ១៨,៦៤% | ១៨,៤៥% | ១៩,២៥% |
| អនុបាតបំណុលធៀបនឹងមូលធន | ៦២៧,០២% | ៦០៥,០៦% | ៥៨៥,៩២% |
| អនុបាតក្របខ័ណ្ឌសន្ទនីយភាព | ២៥០,៧៦% | ១៨០,១៣% | ១៥៤,៩៦% |
| អនុបាតឥណទានមិនដំណើរការ (*) | ៥,៤៧% | ៥,៧៧% | ២,៩០% |
| អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើ | ៨៥,១៧% | ៩២,១១% | ១០០,៥១% |
| តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ១៣.៧៩០ | ១២.៩៧៧ | ១២.៤៥៦ |
| | **ត្រីមាសទី៤ ឆ្នាំ២០២៤** | **ត្រីមាសទី៤ ឆ្នាំ២០២៣** | **ត្រីមាសទី៤ ឆ្នាំ២០២២** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម (ROAA)(**) | ០,៤៥% | ០,៣៨% | ០,៥៦% |
| អនុបាតចំណេញធៀបនឹងមូលធនមធ្យម (ROAE)(**) | ៣,២៧% | ២,៧០% | ៣,៨០% |
| អនុបាតលទ្ធភាពបង់ការប្រាក់ (ដង) | ១,៧៣ | ១,៥២ | ១,៩២ |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល) | ៤៤៤,២០ | ៣៤៧,៤៩ | ៤៦៥ |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | គ្មាន | គ្មាន | គ្មាន |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត | គ្មាន | គ្មាន | គ្មាន |

(*) អនុបាតឥណទានមិនដំណើរការ = សមតុល្យប្រាក់ដើមតាមកិច្ចសន្យារបស់ឥណទានមិនដំណើរការ / សមតុល្យប្រាក់ដើមឥណទានតាមកិច្ចសន្យាសរុប

(**) . អនុបាតទាំងនេះមិនមែនជាអនុបាតប្រចាំឆ្នាំនោះទេ ហើយត្រូវបានគណនាដោយប្រើតួលេខប្រាក់ចំណេញដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគាររយៈពេល ៣ខែ ចាប់ពីថ្ងៃទី០១ ខែតុលា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤។

. អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម = ប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / ទ្រព្យសកម្មសរុបមធ្យម

. អនុបាតចំណេញធៀបនឹងមូលធនមធ្យម = ប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលផ្តល់ជូនដល់ភាគហ៊ុនិករបស់ធនាគារ / មូលធនមធ្យមផ្តល់ជូនភាគហ៊ុនិករបស់ធនាគារ

## ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប






# អនុបាតហិរញ្ញវត្ថុ (%)







ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
៤៦៥
៣៤៧,៤៩
៤៤៤,២០
ត្រីមាសទី៤ ឆ្នាំ២០២២
ត្រីមាសទី៤ ឆ្នាំ២០២៣
ត្រីមាសទី៤ ឆ្នាំ២០២៤


តម្លៃចុះបញ្ជីក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)
១២.៤៥៦
១២.៩៧៧
១៣.៧៩០
ឆ្នាំ២០២២
ឆ្នាំ២០២៣
ត្រីមាសទី៤ ឆ្នាំ២០២៤

## សមាសភាពក្រុមប្រឹក្សាភិបាល



**លោក ឆាយ សឿន**
*ប្រធានក្រុមប្រឹក្សាភិបាល*



**បណ្ឌិត អ៊ិន ចាន់នី**
*អភិបាលប្រតិបត្តិ*



**លោក Stéphane Mangiavacca**
*អភិបាលមិនប្រតិបត្តិ*



**លោក Kyosuke Hattori**
*អភិបាលមិនប្រតិបត្តិ*



**បណ្ឌិត Albertus Bruggink**
*អភិបាលមិនប្រតិបត្តិ*



**លោក Pieter Kooi**
*អភិបាលឯករាជ្យ*



**លោកស្រី ភួរិ រតនា**
*អភិបាលឯករាជ្យ*



**លោក កាយ ឡូត**
*អភិបាលឯករាជ្យ*



**បណ្ឌិត ហេង ឌីណា**
*អភិបាលឯករាជ្យ*

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី (“ធនាគារ អេស៊ីលីដា”) និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមផ្តល់ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសទី៤ ឆ្នាំ២០២៤ របស់ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (“សម្ព័ន្ធធនាគារ”) គិតចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ដល់ភាគីពាក់ព័ន្ធទាំងអស់។

នៅក្នុងកំលុងត្រីមាសទី៤ ឆ្នាំ២០២៤ សេដ្ឋកិច្ចសកលលោកបានបង្ហាញពីស្ថិរភាព និងភាពធន់ជាមួយនឹងកំណើនក្នុងកម្រិតមធ្យម ខណៈដែលអត្រាអតិផរណាឈានដល់កម្រិតគោលដៅ និងការបន្ធូរបន្ថយគោលនយោបាយរូបិយវត្ថុ បានជំរុញកំណើនសេដ្ឋកិច្ចទាំងនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន និងទីផ្សារកំពុងរីកចម្រើន។ ទោះបីជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចសកលលោកអាចនឹងមានសភាពមិនច្បាស់លាស់ ដោយសារភាពតានតឹងផ្នែកភូមិសាស្ត្រនយោបាយដែលកំពុងបន្ត កំណើនយឺតនៃសេដ្ឋកិច្ច និងសញ្ញាណនៃភាពតានតឹងពាណិជ្ជកម្ម។ នៅសហរដ្ឋអាមេរិក សេដ្ឋកិច្ចមានកំណើន២,៧% ដែលបានធ្លាក់ចុះបន្តិចពី២,៨% នៅត្រីមាសទី៣ ដោយសារការចំណាយដ៏សកម្មរបស់អ្នកប្រើប្រាស់ ការវិនិយោគក្រៅពីលំនៅឋាន និងការប្រមូលផ្តុំសារពើភ័ណ្ឌ។ ផលិតផលក្នុងស្រុកសរុបនៅតំបន់អឺរ៉ូមានកំណើនចំនួន ១,៣% ដោយកើនឡើងពី០,៩% នៅក្នុងត្រីមាសមុន ដោយសារតម្រូវការក្នុងស្រុកមានកាន់តែច្រើន ការកែលម្អផលិតកម្មឧស្សាហកម្ម និងការពន្លឿនខ្សែច្រវាក់ផ្គត់ផ្គង់។ ទន្ទឹមនឹងនេះដែរ ផលិតផលក្នុងស្រុកសរុបរបស់ចិនមានការកើនឡើងប្រកបដោយភាពរឹងមាំពីមួយឆ្នាំទៅមួយឆ្នាំ ដោយកើនដល់៤,៩% ក្នុងត្រីមាសទី៤ កើនឡើងពី៤,៦% នៅត្រីមាសទី៣ ដោយសារកំណើនការចំណាយរបស់អ្នកប្រើប្រាស់ ការស្ទុះងើបឡើងវិញ នៃវិស័យអចលនទ្រព្យ និងការវិនិយោគបន្តរបស់រដ្ឋាភិបាលក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធ។ សេដ្ឋកិច្ចអាស៊ានបានបន្តមានដំណើរការល្អគួរឱ្យកោតសរសើរ ដោយសារការកើនឡើងយ៉ាងខ្លាំងនូវតម្រូវការក្នុងស្រុក ការបង្កើនការនាំចេញ កំណើនស្ថិរភាពនៃលំហូរវិនិយោគផ្ទាល់ពីបរទេស និងអត្រាអតិផរណាបានត្រឡប់ទៅរកកម្រិតធម្មតាដូចមុនពេលរីករាលដាលជំងឺកូវីដ-១៩។

ស្របពេលជាមួយគ្នានេះដែរ ការងើបឡើងវិញនៃសេដ្ឋកិច្ចកម្ពុជាមានសន្ទុះខ្លាំង ដោយសារកំណើនការនាំចេញក្នុងវិស័យសំខាន់ៗ ដូចជា សម្លៀកបំពាក់ ស្បែកជើង ការធ្វើដំណើរ និងកសិកម្ម គួបផ្សំនឹងភាពធន់ក្នុងវិស័យមិនមែនកាត់ដេរ លំហូរវិនិយោគឯកជនមានភាពរឹងមាំ និងការងើបឡើងវិញយ៉ាងលឿនក្នុងវិស័យទេសចរណ៍។

ប្រព័ន្ធធនាគាររបស់ប្រទេសកម្ពុជានៅតែមានភាពធន់ និងស្ថិតលើគន្លងនៃកំណើនប្រកបដោយស្ថិរភាព ដោយសារទុនបម្រុងមានភាពរឹងមាំ និងសន្ទនីយភាពមានច្រើន។ ទោះជាយ៉ាងណាក៏ដោយ វិស័យនេះបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន រួមមានការកើនឡើងឥណទានមិនដំណើរការ ការចំណាយខ្ពស់លើមូលនិធិថ្លៃដើម សម្រាប់ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ព្រមទាំងកំណើនឥណទានយឺតជាងការរំពឹងទុក។ ទោះបីជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ រាជរដ្ឋាភិបាល និងធនាគារជាតិ នៃ កម្ពុជា បានដាក់ចេញនូវគោលនយោបាយក្នុងការគាំទ្រទាំងអតិថិជន និងស្ថាប័នក្នុងការធានាស្ថិរភាព ស្របតាមគោលនយោបាយជាតិ និងការត្រួតពិនិត្យជាប្រចាំ។ ស្របពេលជាមួយគ្នានេះដែរ ការរីកចម្រើនក្នុងការផ្លាស់ប្តូរទៅជាឌីជីថល រួមទាំងធនាគារចល័ត និងទំនើបកម្មនៃប្រព័ន្ធទូទាត់ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់វិស័យហិរញ្ញវត្ថុ និងការជំរុញសេដ្ឋកិច្ចឌីជីថល ព្រមទាំងបរិយាបន្នហិរញ្ញវត្ថុ ស្របតាមចក្ខុវិស័យរបស់រដ្ឋាភិបាល និងធនាគារជាតិ នៃ កម្ពុជា។

ធនាគារ អេស៊ីលីដា បាននិងកំពុងបន្តធ្វើឱ្យប្រសើរឡើងនូវមុខងារស្វ័យប្រតិបត្តិការជាច្រើនលើ **អេស៊ីលីដាម៉ូបាល យូអរកូដ** ម៉ាស៊ីនអេធីអឹម និងម៉ាស៊ីនឆូតកាត ស្របតាមតម្រូវការរបស់អតិថិជន ព្រមទាំងវិវឌ្ឍនាការបច្ចេកវិទ្យាឌីជីថលឱ្យក្លាយជា **អេស៊ី ស្មូតអេប**។ ទន្ទឹមនឹងនេះ ធនាគារ អេស៊ីលីដា បានពង្រីកសេវាកម្មធនាគារស្វ័យប្រវត្តិចំនួន **២០៦**ទីតាំង **(៦៣ទីតាំង នៅរាជធានីភ្នំពេញ និង១៤៣ ទីតាំង នៅតាមបណ្តាខេត្ត)** បន្ថែមលើសាខាធនាគារទាំង**២៦៥សាខា** នៅក្នុងប្រទេស។ ធនាគារ អេស៊ីលីដា បានបំពាក់ម៉ាស៊ីនអេធីអឹមចំនួន **១.៤៨៦គ្រឿង** ម៉ាស៊ីនឆូតកាតចំនួន **៥.៥៩៣គ្រឿង** និងយូអរកូដតាមសំណើសុំរបស់អតិថិជន សម្រាប់ប្រតិបត្តិការផ្ទេរប្រាក់ និងទូទាត់នៅតាមបណ្តាផ្សារ ហាងទំនិញ សណ្ឋាគារ ភោជនីយដ្ឋាន គ្រឹះស្ថានសិក្សា មន្ទីរពេទ្យ ទីភ្នាក់ងារទេសចរណ៍ ស្ថានីយប្រេងឥន្ធនៈ និងអាជីវកម្មនានា នៅទូទាំងប្រទេស និងការទូទាត់ឆ្លងប្រទេស (QR Cross Board Payment) ជាបន្តបន្ទាប់។ គិតត្រឹមដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤នេះ ធនាគារ មានអ្នកប្រើប្រាស់ **អេស៊ីលីដាម៉ូបាល** ចំនួនច្រើនជាង **៤,២២ លាននាក់** ជាពិសេសក្នុងនោះ មានដៃគូអាជីវកម្មសរុបជាង **០,៤៩ លាននាក់**។ បន្ថែមលើនេះ ធនាគារបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាជាច្រើនជាមួយនឹងស្ថាប័នរដ្ឋ និងឯកជនជាបន្តបន្ទាប់ ក្នុងការពង្រីកវិសាលភាព និងការផ្តល់ភាពងាយស្រួលក្នុងការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗ។

គិតត្រឹមដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤នេះ ទ្រព្យសកម្មសរុបរបស់សម្ព័ន្ធធនាគារបានកើនឡើងចំនួន **១.០៨៩,៧៩ លានដុល្លារអាមេរិក** ឬ **១១,១៨%** និងទ្រព្យសកម្មឥណទានសរុបបានកើនឡើងចំនួន **៤៦១,៧១ លានដុល្លារអាមេរិក** ឬ **៦,៩៤%** ធៀបនឹងដំណាច់ឆ្នាំ២០២៣។

សម្ព័ន្ធធនាគារ (សម្រាប់ខែតុលា វិច្ឆិកា និងធ្នូ ឆ្នាំ២០២៤) ទទួលបានប្រាក់ចំណេញសរុបចំនួន **៤៧,៥៩ លានដុល្លារអាមេរិក** ខណៈដែលអនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យមមានចំនួន **០,៤៥%** និងអនុបាតចំណេញធៀបនឹងមូលធនមធ្យមមានចំនួន **៣,២៧%**។

ជាទីបញ្ចប់ ខ្ញុំបាទសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះភាគីពាក់ព័ន្ធទាំងអស់ដែលបានបន្តផ្តល់ការជ្រោមជ្រែង និងការគាំទ្រដល់ធនាគារ។

ថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៥

ហត្ថលេខា និងត្រា

**ឆាយ សឿន**

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... i

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... ii

សមាសភាពក្រុមប្រឹក្សាភិបាល ..... v

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ..... vi

ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១

ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១

ខ- លក្ខណៈនៃធុរកិច្ច ..... ១

គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១

ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច ..... ៤

ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ..... ៤

ខ- រចនាសម្ព័ន្ធចំណូល ..... ៦

ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ ..... ៧

ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ..... ៨

ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ..... ៨

ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ..... ១១

គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ..... ១២

ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ..... ១៣

ង- ផលប៉ះពាល់នៃអតិផរណា ..... ១៣

ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល ..... ១៣

ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... ១៦

# ផ្នែកទី១- ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

## ក- អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

| | |
|---|---|
| ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ | **ធនាគារ អេស៊ីលីដា ភីអិលស៊ី** |
| ជាអក្សរឡាតាំង | **ACLEDA BANK PLC.** |
| លេខកូដស្តង់ដារ | KH១០០០១០០០០៣ |
| ទីស្នាក់ការ | អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា |
| លេខទូរស័ព្ទ | +៨៥៥ (០)២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ |
| លេខទូរសារ | +៨៥៥ (០)២៣ ៤៣០ ៥៥៥ |
| គេហទំព័រ | www.acledabank.com.kh |
| អ៊ីម៉ែល | acledabank@acledabank.com.kh |
| លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម | ០០០០៣០៧៧ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០០ ចេញដោយក្រសួងពាណិជ្ជកម្ម |
| លេខអាជ្ញាបណ្ណអាជីវកម្ម | ធ.ព.០៦ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២៣ ចេញដោយ ធនាគារជាតិ នៃ កម្ពុជា |
| សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន | លេខ០៥៣/២០គ.ម.ក./ស.ស.រ. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ចេញដោយនិយ័តករមូលបត្រកម្ពុជា “ន.ម.ក.” (ពីមុនជា គណៈកម្មការមូលបត្រកម្ពុជា “គ.ម.ក.”) |
| ឈ្មោះបុគ្គលតំណាងបុគ្គលចុះបញ្ជីលក់មូលបត្រ | **បណ្ឌិត អ៊ិន ចាន់នី** |

## ខ- លក្ខណៈនៃធុរកិច្ច

ធនាគារ អេស៊ីលីដា គឺជាធនាគារពាណិជ្ជដែលមានសាខា និងបណ្តាញការិយាល័យធំជាងគេបង្អស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារ អេស៊ីលីដា ជាធនាគារពាណិជ្ជទី១ដែលបានចុះបញ្ជីនៅក្នុងផ្សារមូលបត្រកម្ពុជា (ផមក) នៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០។ បច្ចុប្បន្ននេះ ធនាគារមានក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន៤ រួមមាន៖ (១) ធនាគារ អេស៊ីលីដា ឡាវ លីមីតធីត (២) ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (៣) ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក និង (៤) សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រ អេស៊ីលីដា ឯ.ក ព្រមទាំងមានការិយាល័យតំណាងចំនួន១នៅប្រទេសមីយ៉ាន់ម៉ា។

## គ- ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

- នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានទទួលលិខិតថ្លែងអំណរគុណ ពីសមាគមធនាគារនៅកម្ពុជា ដែលធនាគារបានចូលរួមឧបត្ថម្ភគាំទ្រ ការបោះពុម្ពសៀវភៅកម្រងមេរៀនស្តីពីការពង្រឹងសុវត្ថិភាពហិរញ្ញវត្ថុក្នុងសហគមន៍ ក្នុងកម្រិត **"ផ្លាទីនីម"**។
- នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានទទួលលិខិតថ្លែងអំណរគុណពី **ឯកឧត្តម ហ៊ុន ម៉ានី ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ** ជូនចំពោះ **បណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិ** ធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលបានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយស ចែករំលែកបទពិសោធន៍ លើប្រធានបទ "**បរិវត្តកម្ម និងនវានុវត្តន៍ក្នុងការដឹកនាំនិងគ្រប់គ្រងអង្គភាពក្នុងវិស័យឯកជន**" នៅក្នុងកម្មវិធីចែករំលែកឧត្តមានុវត្តន៍ ស្តីពី "**បរិវត្តកម្ម និងនវានុវត្តន៍នៃភាពជាអ្នកដឹកនាំ**" ដែលរៀបចំដោយក្រសួងមុខងារសាធារណៈ។

- នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា មានកិត្តិយស និងសូមស្វាគមន៍យ៉ាងកក់ក្ដៅ ចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្ដម យឹម លាត ទេសាភិបាលរង** ព្រមទាំងថ្នាក់ដឹកនាំ និងសហការី ធនាគារជាតិ នៃ កម្ពុជា បានអញ្ជើញធ្វើទស្សនកិច្ចជាផ្លូវការ នៅការិយាល័យកណ្ដាល ធនាគារ អេស៊ីលីដា។
- នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា ជាធនាគារតែមួយគត់ក្នុងប្រទេសកម្ពុជា ដែលជាប់ជាធនាគារកំពូលទាំង ១.០០០ ទូទាំងពិភពលោក ក្នុងឆ្នាំ២០២៤ ដោយទស្សនាវដ្ដី The Banker។
- នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានទទួលពានរង្វាន់ និងវិញ្ញាបនបត្រផ្ដល់ជូន **បណ្ឌិត អ៊ិន ចាន់នី ប្រធាននាយកប្រតិបត្តិ** ធនាគារ អេស៊ីលីដា ដែលលោកមានស្នាដៃឆ្នើមជា**ស្ថាបនិកធុរកិច្ច ប្រកបដោយភាពច្នៃប្រឌិតខ្ពស់ ប្រចាំឆ្នាំ២០២៤** ពី The Institute of Business Designers នៅទីក្រុង Kolkata ប្រទេសឥណ្ឌា។
- នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានទទួលពានរង្វាន់ **"ភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងមូលបត្រឆ្នើម"** និង **"អភិបាលកិច្ចសាជីវកម្មល្អជាងគេ"** ប្រចាំឆ្នាំ២០២៤ ពីនិយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា នៅក្នុងពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "**My First Stock**" ២០២៤។
- នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានជាប់ជាក្រុមហ៊ុន ដែលមានការបង្ហាញព័ត៌មានសាជីវកម្មឆ្នើម ប្រចាំឆ្នាំ២០២៤ ក្រោមការវាយតម្លៃយ៉ាងល្អិតល្អន់ពីនិយ័តករមូលបត្រកម្ពុជា និងផ្សារមូលបត្រកម្ពុជា នៅក្នុងពិព័រណ៍ផ្សារភាគហ៊ុនកម្ពុជា "**My First Stock**" ២០២៤។
- នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានទទួលលិខិតថ្លែងអំណរគុណ ពីសមាគមធនាគារនៅកម្ពុជា ដែលធនាគារ អេស៊ីលីដា បានឧបត្ថម្ភព្រឹត្តិការណ៍ជិះកង់ របស់សមាគមធនាគារនៅកម្ពុជា ក្រោមប្រធានបទ៖ ជិះកង់ដើម្បីផ្សព្វផ្សាយអំពីនិរន្តរភាពនៃវិស័យធនាគារ និងការលើកកម្ពស់ប្រាក់រៀល។
- នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា មានមោទនភាពប្រកាសបើកសាខាក្រុមហ៊ុនក្នុងស្រុក **(សាខាទី២៦៥)** ស្ថិតក្នុងឃុំប្រម៉ោយ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ ការពង្រីកប្រតិបត្តិការសាខាថ្មីនេះ ឆ្លុះបញ្ចាំងពីការប្ដេជ្ញាចិត្តរបស់យើងខ្ញុំ ក្នុងការផ្ដល់ជូននូវផលិតផលនិងសេវាកម្ម ប្រកបដោយនវានុវត្តន៍ និងសុវត្ថិភាពខ្ពស់ ជូនដល់អតិថិជន និងសាធារណជន គ្រប់មជ្ឈដ្ឋានក្នុងសហគមន៍។
- នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា ជាធនាគារពាណិជ្ជខ្មែរដ៏ធំជាងគេមួយនៅកម្ពុជា ថ្មីៗនេះបានក្លាយជាធនាគារខ្មែរតែមួយគត់នៅក្នុងប្រទេសកម្ពុជា ដែលបានឈ្នះពានរង្វាន់ធនាគារដែលមានសុវត្ថិភាពបំផុត នៅលើពិភពលោកឆ្នាំ២០២៤ ពីទស្សនាវដ្ដី Global Finance។ ការផ្ដល់ពានរង្វាន់នេះ ត្រូវបានទស្សនាវដ្ដី Global Finance អះអាងថា មានការឆ្លងកាត់ការវាយតម្លៃយ៉ាងល្អិតល្អន់ទៅលើចំណាត់ថ្នាក់រូបិយវត្ថុអន្តរជាតិរយៈពេលវែង (long-term foreign currency ratings) ឬចំណាត់ថ្នាក់បំណុល ដែលត្រូវបានចាត់ថ្នាក់ដោយស្ថាប័នវាយតម្លៃហិរញ្ញវត្ថុ Fitch, Moody's និង Standard & Poor's នៅក្នុងចំណោមធនាគារធំបំផុតទាំង ៥០០ នៅទូទាំងពិភពលោក។
- នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២៤ ថ្នាក់ដឹកនាំ និងកម្មករនិយោជិតធនាគារ អេស៊ីលីដា គ្រប់លំដាប់ថ្នាក់នៅការិយាល័យកណ្ដាល និងសាខាជុំវិញរាជធានីភ្នំពេញ បានចូលរួមបរិច្ចាគឈាមដោយស្ម័គ្រចិត្ត ដើម្បីជួយសង្គ្រោះជនរងគ្រោះ និងអ្នកជំងឺ ដែលត្រូវការឈាម។ នេះសបញ្ជាក់ឱ្យឃើញថា ធនាគារបានចូលរួមចំណែកក្នុងសកម្មភាពសង្គម និងមនុស្សធម៌ សម្រាប់បំពេញតម្រូវការកង្វះឈាមក្នុងការជួយសង្គ្រោះអាយុជីវិតជូនដល់មជ្ឈមណ្ឌលជាតិផ្ដល់ឈាម។
- នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានទទួលពានរង្វាន់ ដៃគូប្រតិបត្តិការទូទាត់ឆ្នើម (STP) ប្រចាំឆ្នាំ២០២៣ ពី The Bank of New York Mellon (BNY)។ ពានរង្វាន់នេះបង្ហាញពីសមិទ្ធផលដ៏ល្អឥតខ្ចោះ របស់ធនាគារ អេស៊ីលីដា ក្នុងការបម្រើសេវាទូទាត់ សម្រាប់ទម្រង់បែបបទ MT103/MT202។
- នៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានចុះអនុស្សរណៈនៃការយោគយល់គ្នា ស្ដីពីភាពជាដៃគូយុទ្ធសាស្ត្រ និងកិច្ចសហប្រតិបត្តិការលើការផ្ដល់សេវាកម្មសុខាភិបាល ដ៏មានគុណភាពស្របតាមស្តង់ដារអន្តរជាតិ ជូនថ្នាក់ដឹកនាំ បុគ្គលិក ព្រម

ទាំងក្រុមគ្រួសារបុគ្គលិក និងអតិថិជននៃធនាគារ អេស៊ីលីដា រវាង មន្ទីរពេទ្យអន្តរជាតិ អរៀនដា ជាមន្ទីរពេទ្យស្តង់ដារអន្តរជាតិដ៏ឈានមុខមួយក្នុងចំណោមមន្ទីរពេទ្យនានា នៅក្នុងប្រទេសកម្ពុជា។

- នៅថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៤ លោក ឆាយ យ៉ារដ្ឋ នាយកប្រតិបត្តិសន្តិសុខព័ត៌មានវិទ្យា ធនាគារ អេស៊ីលីដា បានទទួលពានរង្វាន់ **CSO30 ASEAN Award** ប្រចាំឆ្នាំ២០២៤។
- នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានទទួលលិខិតថ្លែងអំណរគុណ ពីសហគ្រិនខ្មែរ ដែលធនាគារ អេស៊ីលីដា បានចូលរួមឧបត្ថម្ភ **"ទិវាប្រព័ន្ធអេកូឡូស៊ី សហគ្រិនភាព ឆ្នាំ២០២៤"**។
- នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានទទួលវិញ្ញាបនបត្រសុវត្ថិភាពប្រព័ន្ធព័ត៌មានវិទ្យា និងការរក្សាឯកជនភាពនៃទិន្នន័យខ្ពស់ឈានមុខគេ កម្រិតស្តង់ដារអន្តរជាតិ ISO/IEC 27701:2019 និង ISO/IEC 27001:2022។ សមិទ្ធផលទាំងនេះជាសក្ខីភាពបង្ហាញពីការប្តេជ្ញាចិត្តរបស់ធនាគារ អេស៊ីលីដា ក្នុងនាមជាធនាគារខ្មែរឈានមុខគេក្នុងប្រទេសកម្ពុជា ដើម្បីរក្សា និងការពារការសម្ងាត់ សុចរិតភាព តម្លាភាព និងឯកជនភាពនៃព័ត៌មានរបស់អតិថិជន។
- នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានចុះអនុស្សរណៈនៃការយោគយល់គ្នា ជាមួយក្រសួងពាណិជ្ជកម្ម ស្តីពីការប្រើប្រាស់សេវាកម្មទូទាត់ប្រាក់តាមប្រព័ន្ធអេឡិចត្រូនិករបស់ធនាគារ អេស៊ីលីដា សម្រាប់ការទូទាត់ប្រតិបត្តិការទិញ-លក់ទំនិញលើផ្សារខេមបូឌាត្រេដ ដើម្បីផ្តល់ភាពងាយស្រួល រហ័ស និងសុវត្ថិភាព ព្រមទាំងជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក ក្នុងផ្សារខេមបូឌាត្រេដ។
- នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានទទួលរបាយការណ៍វាយតម្លៃពីភ្នាក់ងារវាយតម្លៃអន្តរជាតិ **Standard & Poor's (S&P) Global Ratings** ដោយរក្សាបានចំណាត់ថ្នាក់ **"B+/Stable/B"** ដដែល។ ការរក្សាបានចំណាត់ថ្នាក់នេះ សបញ្ជាក់អំពីភាពរឹងមាំ និងការរក្សាបានស្ថិរភាពប្រវត្តិហិរញ្ញវត្ថុរបស់ធនាគារ អេស៊ីលីដា ក្នុងរយៈពេលវែង ជាមួយនឹងទ្រនាប់ដើមទុនគ្រប់គ្រាន់ និងការរក្សាបានស្ថិរភាពដើមទុនរបស់ខ្លួន សម្រាប់ឆ្លើយតបគ្រប់ស្ថានភាពសេដ្ឋកិច្ច។
- នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានទទួលលិខិតថ្លែងអំណរគុណ ពីសមាគមធនាគារនៅកម្ពុជា ដែលធនាគារ អេស៊ីលីដា បានឧបត្ថម្ភក្នុងកម្មវិធី **"ពិធីលៀងសាយភោជន ប្រចាំឆ្នាំ២០២៤"**។
- នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នាជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល ស្តីពីកិច្ចសហប្រតិបត្តិការលើការចុះឈ្មោះអ្នកសេដ្ឋកិច្ចក្រៅប្រព័ន្ធ តាមរយៈថ្នាលឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ អនុស្សរណៈ នៃការយោគយល់គ្នានេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ក្នុងការចូលរួមអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកកម្ពស់ការគាំពារ និងការពង្រឹងសមត្ថភាពផលិតភាព និងភាពធន់ នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ ព្រមទាំងជំរុញកំណើនសេដ្ឋកិច្ចជាតិ។
- នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានចុះហត្ថលេខារួមគ្នាលើអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងមហាផ្ទៃ ស្តីពីការប្រើប្រាស់សេវាកម្មទូទាត់តាមឌីជីថល និងម៉ាស៊ីនឆូតបណ្ណ ឬកាត (POS Terminal) របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ប្រមូលកម្រៃទិដ្ឋាការពីអតិថិជន **(Visa on Arrival)**។ អនុស្សរណៈនៃការយោគយល់គ្នានេះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់ ដោយតភ្ជាប់ទៅនឹងវិវឌ្ឍនាការនៃប្រព័ន្ធបច្ចេកវិទ្យាទំនើបឆ្ពោះទៅរកសេដ្ឋកិច្ចឌីជីថល ព្រមទាំងផ្តល់មធ្យោបាយយ៉ាងទូលំទូលាយ ប្រកបដោយភាពងាយស្រួល និងសុវត្ថិភាពខ្ពស់ ជូនដល់អ្នកដំណើរអន្តរជាតិ ដែលធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ដើម្បីទទួលបានទិដ្ឋាការភ្លាមៗពេលមកដល់អាកាសយានដ្ឋានអន្តរជាតិនានារបស់កម្ពុជា។
- នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា បានដាក់ឱ្យដំណើរការកម្មវិធី WeChat Pay សម្រាប់អ្នកដំណើរជនជាតិចិនទូទាត់កម្រៃទិដ្ឋាការ **(Visa on Arrival)**។ ការដាក់ឱ្យដំណើរការមធ្យោបាយទូទាត់តាមប្រព័ន្ធ **"Wechat Pay"** សម្រាប់ការប្រមូលកម្រៃទិដ្ឋាការពីអតិថិជនតាមប្រព័ន្ធអេឡិចត្រូនិកសលាកបត្រចូលព្រះរាជាណាចក្រកម្ពុជា ក្រោមកិច្ចសហការរវាង ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារពាណិជ្ជឈានមុខគេនៅកម្ពុជា និងក្រុមហ៊ុន TENCENT តាមរយៈការទូទាត់តាមប្រព័ន្ធអេឡិចត្រូនិក របស់ធនាគារ អេស៊ីលីដា ដោយប្រើមធ្យោបាយទូទាត់អន្តរជាតិរបស់ NETSTAR **“StarPay”**។

## ផ្នែកទី២- ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ក- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

- **<u>ប្រតិបត្តិការក្នុងវិស័យធនាគារ</u>**

ត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៤ ធនាគារពាណិជ្ជមានចំនួន៥៩ (ធនាគារក្នុងស្រុកចំនួន២៨ បុត្រសម្ព័ន្ធធនាគារបរទេសចំនួន២០ និងសាខាធនាគារបរទេសចំនួន១១) ធនាគារឯកទេសចំនួន០៩ (ធនាគារក្នុងស្រុកចំនួន០៤ និងធនាគារបរទេសចំនួន០៥) គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន៨៩ (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន០៤ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមិនទទួលប្រាក់បញ្ញើចំនួន៨៥) ក្រុមហ៊ុនភតិសន្យាចំនួន១៤ ការិយាល័យតំណាងធនាគារបរទេសចំនួន០៥ គ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ចំនួន៣៣ គ្រឹះស្ថានឥណទានជនបទចំនួន១១៥ និងភ្នាក់ងារប្តូរប្រាក់ចំនួន៣.៣៥០។ (Source: NBC Report, CMA Report, Actually Updated)

- **<u>ប្រតិបត្តិការអាជីវកម្ម និងចំណែកទីផ្សាររបស់ធនាគារ អេស៊ីលីដា នៅក្នុងវិស័យធនាគារ</u>**

គិតត្រឹមដំណាច់ខែវិច្ឆិកា ឆ្នាំ២០២៤ ធនាគារ អេស៊ីលីដា មានចំណែកទីផ្សារសម្រាប់ប្រាក់បញ្ញើសន្សំចំនួន ១៤,២៨% និងសម្រាប់ឥណទានចំនួន ១២,២២%។

គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២៤ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួនទទួលបានលទ្ធផលសំខាន់ៗ ដូចខាងក្រោម៖

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២៤ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
| **សេវាឥណទាន** | | | |
| ចំនួនឥណទានសកម្ម | ៧៣៣.៥៤៩ | ៦៦១.៩៤១ | ៥៩១.៤៩៤ |
| សមតុល្យឥណទានសរុប (លានរៀល) | ២៨.៦៥៤.០៦៨ | ២៧.១៩៥.១២០ | ២៦.៤៣៧.៩២៨ |
| **សេវាបញ្ញើ-សន្សំ** | | | |
| ចំនួនគណនីសរុប | ៥.៥២៥.០៨៦ | ៤.៥៥០.៥៨២ | ៣.៨៦៥.៧៤៩ |
| សមតុល្យប្រាក់បញ្ញើសរុប (លានរៀល) | ៣៣.៦៤៥.២០០ | ២៩.៥២៥.៦១៦ | ២៦.៣០៣.៤៧៥ |
| **សេវាធនាគារអេឡិចត្រូនិក** | | | |
| **ប័ណ្ណអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណបោះផ្សាយសរុប | ១.៨០២.៤១៨ | ១.៩៣៩.០៩៨ | ១.៧៩៩.៩០៩ |
| ចំនួនប្រតិបត្តិការសរុប | ១៧.១០៧.៧៨៨ | ១៩.៨៥១.៨០១ | ២១.០៥៨.៦០៩ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៥.៦៨៥.០០៦ | ១៧.១៤៥.៤១១ | ១៨.៦៨៣.៣៣៥ |
| **អេស៊ីលីដាម៉ូបាល** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ៤.៩០០.៥២៤ | ៣.៨៥១.៦០៦ | ២.៨៤៥.៨៨៦ |
| ចំនួនប្រតិបត្តិការសរុប | ៩២២.៧៩៣.៥១១ | ៣៧៣.០៣៦.៣៣៦ | ១៤៨.៧៩៩.៦៦១ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៦៣១.០១២.៣៣៤ | ៣៨៣.០៤៣.៥៩៦ | ២០៦.៦៦០.២៦២ |
| **អេស៊ីលីដាអ៊ីនធើណែត** | | | |
| ចំនួនអ្នកប្រើប្រាស់សរុប | ២៤.០៣៣ | ២៤.៨២៥ | ២២.១៦៤ |
| ចំនួនប្រតិបត្តិការសរុប | ៥.០៣៧.១៤២ | ៣.៥២៩.២០៩ | ២.៣១៨.៧៨៩ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៣៥.៣១៨.៥៧៨ | ២៦.៥២៩.៣៨១ | ២៦.១៩៨.៧០៥ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២៤ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
| **អេស៊ីលីដាអ៊ីខុមមើស** | | | |
| ចំនួនដៃគូអាជីវកម្មសរុប | ១៦៤ | ៨៨ | ៧៣ |
| ចំនួនប្រតិបត្តិការសរុប | ៣.២៩៧.៣០៩ | ៣.៩៨៣.១៦៧ | ៣.៦១៩.៩៣៦ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ២.០១៦.៦០១ | ២.០១៩.០០១ | ១.៨០៤.១៣៦ |
| **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនសរុប | ១.៤១៦ | ១.៣១៤ | ១.១១៤ |
| ចំនួនប្រតិបត្តិការសរុប | ៦៩.៥៤៥.៤៨៧ | ៤១.៥៥៤.៩៩៣ | ៣៥.២៩៨.២១៤ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៨៥.៥៤៩.៩៣៤ | ៤៦.៨០១.៩៨២ | ៣៩.១៦០.៩៧៦ |
| **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** | | | |
| ចំនួនម៉ាស៊ីនសរុប | ២៦ | ២៦ | ២៦ |
| ចំនួនប្រតិបត្តិការសរុប | ១៨៥ | ៣០៤ | ១.៤៨៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១១.០៧២ | ១៦.១៤៣ | ១១១.១៣៤ |
| **ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម** | | | |
| ចំនួនម៉ាស៊ីនសរុប | ៩៦ | ៩៦ | ៤៣ |
| ចំនួនប្រតិបត្តិការសរុប | ១៥៤.៤៨០ | ១៣០.៩៨៧ | ៤៣.០៨៩ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១ | ៥ | ១៦ |
| **ម៉ាស៊ីនទទួលកាបូបប្រាក់** | | | |
| ចំនួនម៉ាស៊ីនសរុប | ១៧ | ១៧ | ១៧ |
| ចំនួនប្រតិបត្តិការសរុប | ៩០.០២៧ | ៨៨.៩០៨ | ៧៥.០២០ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៤០១.៨១៤ | ៥០៦.៥៥០ | ៥៧១.០៩៨ |
| **ម៉ាស៊ីនឆូតកាតអេស៊ីលីដា** | | | |
| ចំនួនម៉ាស៊ីនឆូតកាតសរុប | ៥.៥៥៣ | ៤.៧២៨ | ៤.៣៥៨ |
| ចំនួនប្រតិបត្តិការសរុប | ៥.៦៨៣.២៤៧ | ១.៩០០.៤០០ | ២.១៥៩.១៧៥ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១.០៩៥.៥០៣ | ៦១៤.៤០៣ | ៥៩១.៦០៣ |
| **ឃ្យូអរ ពាណិជ្ជករ** | | | |
| ចំនួនពាណិជ្ជករ | ៥៥៥.៥៥៤ | ៣៨២.២១៧ | ២៣៩.៧៥១ |
| ចំនួនប្រតិបត្តិការសរុប | ៤១៣.៩០៥.៦៥៥ | ១១០.១៤៨.៨៤៨ | ១៦.៤៥៩.៣៧៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១៤៥.០០២.៥៩១ | ៦៣.១៧៥.៧២០ | ៧.៧៧៧.៤៩១ |

| លទ្ធផលសំខាន់ៗ | លទ្ធផលសម្រេចបាន | | |
|---|---|---|---|
| | ត្រីមាសទី៤ ឆ្នាំ២០២៤ | ឆ្នាំ២០២៣ | ឆ្នាំ២០២២ |
| **បណ្ណនិម្មិតអេស៊ីលីដា** | | | |
| ចំនួនប័ណ្ណនិម្មិត | ៤៥.២៧៥ | ២៧.១០៦ | ៨.៨៩៨ |
| ចំនួនប្រតិបត្តិការសរុប | ៧៦៨.២៦០ | ១៨២.៣៧៦ | ៣៤.៩០៧ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ៩៧.៣៩៦ | ១៨.៨១៨ | ៣.០១៨ |
| **ខ្សែអាយប៊ែង** | | | |
| ចំនួនខ្សែបោះផ្សាយសរុប | ១០.៥១៣ | ១០.៦០៣ | ៤.៩៦០ |
| ចំនួនប្រតិបត្តិការសរុប | ៤.៣៣៥ | ១២.៧១០ | ១៨.៧៤២ |
| ទំហំទឹកប្រាក់សរុប (លានរៀល) | ១២.៥៥៩ | ១៤.៥១១ | ៣១.៧៦២ |
| **បណ្ដាញប្រតិបត្តិការ និង បុគ្គលិក** | | | |
| **ធនាគារ អេស៊ីលីដា ភីអិលស៊ី** | | | |
| ចំនួនការិយាល័យសរុប | ២៦៥ | ២៦៤ | ២៦៤ |
| ចំនួនធនាគារស្វ័យប្រវត្តិ | ២០៦ | ១៧៧ | ១២៥ |
| ចំនួនបុគ្គលិកសរុប | ១១.៩៧១ | ១២.០៤៥ | ១២.០៨៣ |
| **ក្រុមហ៊ុនបុត្រសម្ព័ន្ធ (ក្នុង និង ក្រៅប្រទេស)** | | | |
| ចំនួនការិយាល័យសរុប | ៥៦ | ៥៦ | ៥៦ |
| ចំនួនបុគ្គលិកសរុប | ១.៤៨៣ | ១.៤៥៨ | ១.៤៩៩ |

## ខ- រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៤ | | ត្រីមាសទី៤ ឆ្នាំ២០២៣ | | ត្រីមាសទី៤ ឆ្នាំ២០២២ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៨៤៦.៩៣៨ | ៩៤,៤១% | ៨០០.៩៥០ | ៩១,៦៣% | ៧៣៤.៤៦០ | ៩១,៣៣% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៤.០៧៦ | ៤,៩១% | ៤៧.៩០២ | ៥,៤៨% | ៤៦.៧៨៩ | ៥,៨២% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ៦.០៥៧ | ០,៦៨% | ២៥.២៥០ | ២,៨៩% | ២២.៩០៩ | ២,៨៥% |
| | **ចំណូលសរុប** | **៨៩៧.០៧១** | **១០០%** | **៨៧៤.១០២** | **១០០%** | **៨០៤.១៥៨** | **១០០%** |

# ផ្នែកទី៣- របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនកររងករាជ្យ

សូមពិនិត្យមើលឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ
របាយការណ៍ហិរញ្ញវត្ថុដែលត្រូវបានធ្វើសវនកម្មដោយសវនកររងករាជ្យ

## ផ្នែកទី៤- ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះផ្តោតសំខាន់លើលទ្ធផលប្រតិបត្តិការ និងលទ្ធផលហិរញ្ញវត្ថុដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេលគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ដែលត្រូវបានធ្វើសវនកម្មដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុចន្លោះពេលត្រូវបានរៀបចំឡើងដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”)។ មានតែសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុចន្លោះពេល និងកត្តាសំខាន់ៗដែលប៉ះពាល់ដល់ប្រាក់ចំណេញរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (“សម្ព័ន្ធធនាគារ”) ប៉ុណ្ណោះ ត្រូវបានយកមកធ្វើការពិភាក្សា និងវិភាគ។

## ក- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

### ១- ការវិភាគចំណូល

សម្ព័ន្ធធនាគារ មានប្រភពចំណូលធំៗចំនួនបីគឺ ចំណូលការប្រាក់ ចំណូលកម្រៃនិងជើងសា និងចំណូលផ្សេងៗសុទ្ធ។

- ចំណូលការប្រាក់៖ រួមមានចំណូលការប្រាក់ពីឥណទាននិងបុរេប្រទាន ចំណូលការប្រាក់ពីប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងការវិនិយោគហិរញ្ញវត្ថុ។
- ចំណូលកម្រៃនិងជើងសា៖ រួមមានកម្រៃជើងសា កម្រៃជើងសាបានពីភ្នាក់ងារធានារ៉ាប់រង កម្រៃពីម៉ាស៊ីនអេធីអឹម កម្រៃពីការសងឥណទានមុនកាលកំណត់ កម្រៃពីសេវាប្រាក់បញ្ញើ កម្រៃពីសេវាធានា និងកម្រៃពីការបណ្តុះបណ្តាល។
- ចំណូលផ្សេងៗសុទ្ធ៖ រួមមានចំណេញពីការប្តូររូបិយប័ណ្ណ-សុទ្ធ ចំណេញពីការលក់ទ្រព្យសម្បត្តិនិងបរិក្ខារនិងភតិសន្យា ភាគលាភលើការវិនិយោគហិរញ្ញវត្ថុ និងចំណូលផ្សេងៗ។

### ២- ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៤ | | ត្រីមាសទី៤ ឆ្នាំ២០២៣ | | ត្រីមាសទី៤ ឆ្នាំ២០២២ | |
|---|---|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | ចំណូលការប្រាក់ | ៨៤៦.៩៣៨ | ៩៤,៤១% | ៨០០.៩៥០ | ៩១,៦៣% | ៧៣៤.៤៦០ | ៩១,៣៣% |
| ២ | ចំណូលកម្រៃនិងជើងសា | ៤៤.០៧៦ | ៤,៩១% | ៤៧.៩០២ | ៥,៤៨% | ៤៦.៧៨៩ | ៥,៨២% |
| ៣ | ចំណូលផ្សេងៗសុទ្ធ | ៦.០៥៧ | ០,៦៨% | ២៥.២៥០ | ២,៨៩% | ២២.៩០៩ | ២,៨៥% |
| | **ចំណូលសរុប** | **៨៩៧.០៧១** | **១០០%** | **៨៧៤.១០២** | **១០០%** | **៨០៤.១៥៨** | **១០០%** |

ចំណូលសរុបនៅត្រីមាសទី៤ ឆ្នាំ២០២៤ បានកើនឡើងចំនួន ២២,៩៧ ប៊ីលានរៀល ឬ ២,៦៣% បើប្រៀបធៀបទៅនឹងត្រីមាសទី៤ ឆ្នាំ២០២៣ ដែលការកើនឡើងទាំងនេះគឺដោយសារប្រសិទ្ធភាពនៃផលិតផល និងសេវាកម្មដ៏សម្បូរបែបរបស់ធនាគារក្នុងយុគសម័យឌីជីថល និងកំណើនអតិថិជន។

### ៣- ការវិភាគគម្លាតចំណេញដុល

របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរបស់សម្ព័ន្ធធនាគារ ត្រូវបានរៀបចំក្នុងទម្រង់ជារបាយការណ៍ដែលមិនបង្ហាញពីគម្លាតចំណេញដុលទេ។ ចំណូលការប្រាក់សុទ្ធដែលទទួលបានមកពីចំណូលការប្រាក់សរុបដកនឹងចំណាយការប្រាក់សរុប នឹងត្រូវយកមកបង្ហាញនៅក្នុងការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ ដូចខាងក្រោម។

## ៤- ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៤ | ត្រីមាសទី៤ ឆ្នាំ២០២៣ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| ចំណូលការប្រាក់ | ៨៤៦.៩៣៨ | ៨០០.៩៥០ | ៤៥.៩៨៨ | ៥,៧៤% |
| ចំណាយការប្រាក់ | (៣៤០.៤២៧) | (៣៥៨.៦៤៣) | ១៨.២១៦ | (៥,០៨%) |
| **ចំណូលការប្រាក់សុទ្ធ** | **៥០៦.៥១០** | **៤៤២.៣០៧** | **៦៤.២០៣** | **១៤,៥២%** |
| ចំណូលកម្រៃនិងជើងសា | ៤៤.០៧៦ | ៤៧.៩០២ | (៣.៨២៦) | (៧,៩៩%) |
| ចំណាយកម្រៃនិងជើងសា | (២.៦២៦) | (៣.៨៧៣) | ១.២៤៧ | (៣២,២០%) |
| **ចំណូលកម្រៃនិងជើងសាសុទ្ធ** | **៤១.៤៤៩** | **៤៤.០៣០** | **(២.៥៨១)** | **(៥,៨៦%)** |
| សំវិធានធននៃការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាននិងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗ គណនីត្រូវទទួល និងមូលបត្រវិនិយោគផ្សេងៗ | (៥.៩៨៧) | (៤៧.៩៣៣) | ៤១.៩៤៦ | (៨៧,៥១%) |
| សំវិធានធននៃការខាតបង់ឱនភាពនៃតម្លៃរបស់កិច្ចសន្យាក្រៅតារាងតុល្យការ | ២ | (២) | ៤ | (២០០%) |
| **ការខាតបង់ឱនភាពនៃតម្លៃសុទ្ធ** | **(៥.៩៨៥)** | **(៤៧.៩៣៥)** | **៤១.៩៥០** | **(៨៧,៥១%)** |
| **ចំណូលបន្ទាប់ពីការខាតបង់ឱនភាពនៃតម្លៃ** | **៥៤១.៩៧៥** | **៤៣៨.៤០២** | **១០៣.៥៧៣** | **២៣,៦៣%** |
| ចំណូលផ្សេងៗសុទ្ធ | ៦.០៥៧ | ២៥.២៥០ | (១៩.១៩៣) | (៧៦,០១%) |
| ចំណាយប្រតិបត្តិការផ្សេងៗ | (២៩៩.៨១២) | (២៧៧.៥៤៥) | (២២.២៦៧) | ៨,០២% |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **២៤៨.២១៩** | **១៨៦.១០៧** | **៦២.១១២** | **៣៣,៣៧%** |

ការកើនឡើងនូវតម្រូវការទុនអាជីវកម្មរបស់អតិថិជន បានធ្វើឱ្យឥណទានរបស់សម្ព័ន្ធធនាគារនៅត្រីមាសទី៤ ឆ្នាំ២០២៤ កើនឡើងចំនួន ២៤២លានដុល្លារអាមេរិក ស្របពេលដែលគុណភាពឥណទានមានភាពល្អប្រសើរឡើង។

## ៥- ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| របាយការណ៍ចំណេញ ឬខាត (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៤ | ត្រីមាសទី៤ ឆ្នាំ២០២៣ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ** | **២៤៨.២១៩** | **១៨៦.១០៧** | **៦២.១១២** | **៣៣,៣៧%** |
| ចំណាយពន្ធលើប្រាក់ចំណេញ | (៥៥.៥២៨) | (៣៥.៤៩៦) | (២០.០៣២) | ៥៦,៤៣% |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៩២.៦៩២** | **១៥០.៦១២** | **៤២.០៨០** | **២៧,៩៤%** |

## ៦- ការវិភាគលទ្ធផលលម្អិតក្នុងការិយបរិច្ឆេទ

| លទ្ធផលលម្អិតសរុប (លានរៀល) | ត្រីមាសទី៤ ឆ្នាំ២០២៤ | ត្រីមាសទី៤ ឆ្នាំ២០២៣ | គម្លាត | |
|---|---|---|---|---|
| | | | ចំនួន | ភាគរយ |
| **ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ** | **១៩២.៦៩២** | **១៥០.៦១២** | **៤២.០៨០** | **២៧,៩៤%** |
| **លទ្ធផលចំណេញលម្អិតផ្សេងៗ៖** | | | | |
| ***ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញ ឬខាត៖*** | | | | |
| លម្អៀងពីអត្រាប្តូរប្រាក់ | (៥៣.៥៧៣) | (៥១.០៣០) | (២.៥៤៣) | (៤,៩៨%) |
| ***ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅគ្រាបន្ទាប់ទៅចំណេញ ឬខាត៖*** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ-ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស | ៣១.៥៩៤ | ៤.៣០៤ | ២៧.២៩០ | ៦៣៤,០៦% |
| ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធភាពរបស់ឧបករណ៍និស្សន្ទដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់ | (៤.២៥២) | (១២.៣៧៧) | ៨.១២៥ | ៦៥,៦៥% |
| **លទ្ធផល(ខាត)/ចំណេញលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ** | **(២៦.២៣១)** | **(៥៩.១០៣)** | **៣២.៨៧២** | **៥៥,៦២%** |
| **លទ្ធផលចំណេញលម្អិតសរុបក្នុងការិយបរិច្ឆេទ** | **១៦៦.៤៦០** | **៩១.៥០៩** | **៧៤.៩៥១** | **៨១,៩១%** |

## ៧- ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

ធនាគារ អេស៊ីលីដា មានទំនុកចិត្តក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការរបស់ខ្លួន ចំពេលការព្យាករកំណើនសេដ្ឋកិច្ចមានសញ្ញាល្អប្រសើរឡើង បន្ទាប់ពីបានកសាងកេរ្តិ៍ដំណែលដ៏រឹងមាំអស់រយៈពេលច្រើនជាង៣០ឆ្នាំកន្លងមកនេះ ធនាគារ អេស៊ីលីដា បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ពេលអនាគត ហើយនឹងនៅតែបន្តចាក់គ្រឹះឱ្យកាន់តែរឹងមាំដើម្បីផ្តល់ជូននូវដំណោះស្រាយក្នុងវិស័យធនាគារឱ្យកាន់តែសម្បូរបែប ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរតម្រូវការផ្នែកហិរញ្ញវត្ថុរបស់អតិថិជនទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជា។

បន្ទាប់ពីបំបែកព្រំដែនភូមិសាស្ត្រ ដោយការដាក់បញ្ចូលនូវហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងរូបវន្ត ធនាគារដែលបានបង្កើតឡើងនៅក្នុងស្រុកមួយនេះ កំពុងផ្តល់ជូននូវសេវាកម្មធនាគារសម្រាប់មូលដ្ឋានអតិថិជនចម្រុះដោយជោគជ័យ ដែលមានរាប់ចាប់តាំងពីសេវាធនាគារបុគ្គល និងសម្រាប់សាជីវកម្ម ទាំងនៅក្នុងទីក្រុង រហូតដល់តំបន់ជនបទ។ ជាមួយនឹងភាពលេចធ្លោក្នុងការផ្តល់ជូននូវសេវាកម្មហិរញ្ញវត្ថុដ៏សម្បូរបែប ដូចជាផ្តល់ប្រាក់កម្ចី ផ្ទេរប្រាក់ ប្រាក់បញ្ញើ ហិរញ្ញប្បទានពាណិជ្ជកម្ម អេស៊ីលីដាអ៊ីនធើណែត **អេស៊ីលីដា ម៉ូបាល** និងសេវាសំខាន់ជាច្រើនទៀត គាំទ្រដោយហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការិយាល័យរូបវន្តរបស់ខ្លួន ធនាគារ អេស៊ីលីដា កំពុងចូលរួមយ៉ាងសកម្មក្នុងការជួយដល់កសិករ តាមរយៈការផ្តល់ដើមទុនសម្រាប់ធ្វើស្រែចម្ការរបស់គាត់ ឬផ្តល់ទុនសម្រាប់សហគ្រាសធុនតូច និងមធ្យមជាដើម។ តាមរយៈការបង្រួមគម្លាតចំពោះការទទួលបានហិរញ្ញប្បទាន សព្វថ្ងៃនេះប្រជាជនកម្ពុជាច្រើនជាង៦សែននាក់ មានលទ្ធភាពប្រើប្រាស់សេវារបស់ធនាគារ អេស៊ីលីដា ដែលជាការជំរុញ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុនៅព្រះរាជាណាចក្រកម្ពុជា។

បន្ទាប់ពីរយៈពេលច្រើនជាង៣០ឆ្នាំមកនេះ គេនឹងមើលឃើញ ធនាគារ អេស៊ីលីដា គឺជាធនាគារឌីជីថល ដែលមានវិស្វកម្មគ្រប់គ្រងទិន្នន័យទំនើបទាន់សម័យ (Data Lakehouse) ប្រកបដោយគុណភាព សុវត្ថិភាព និងទំនុកចិត្ត។ ប្រព័ន្ធអេកូនៃបណ្តាញប្រកបដោយប្រសិទ្ធភាពរបស់ធនាគារនៅទូទាំងប្រទេស រួមមានម៉ាស៊ីន ATM ទីតាំងធនាគារស្វ័យប្រវត្តិ ម៉ាស៊ីនដក-ដាក់ប្រាក់ ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់ កំពុងដើរតួជាកាតាលីករដ៏មានឥទ្ធិពលមួយសម្រាប់រលកនៃកំណើនបន្ទាប់។

អនាគតរបស់ធនាគារនឹងកាន់តែរឹងមាំ ខណៈទំនុកចិត្តរបស់អាជីវកម្មលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជានឹងកើនឡើង បន្ទាប់ពីរាជរដ្ឋាភិបាលបានទប់ស្កាត់ការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ការងើបឡើងវិញនៃការនាំចេញផ្នែកផលិតកម្ម និងការពង្រីកការនាំចេញទំនិញកសិកម្ម នឹងមានភាពល្អប្រសើរសម្រាប់ធនាគារ អេស៊ីលីដា ដោយសារអ្នកទទួលកម្ចីភាគច្រើនមានអាជីវកម្មទាក់ទងនឹងកសិផល។ ធនាគារនឹងសម្រេចបានលទ្ធផលកាន់តែល្អប្រសើរនៅក្នុងឆ្នាំ២០២៤ ដោយសារធនាគារបានវិនិយោគយ៉ាងច្រើនទៅលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល សាងសង់មជ្ឈមណ្ឌលទិន្នន័យដ៏ធំមួយ ដែលមានសុវត្ថិភាពខ្ពស់ដើម្បីរក្សាទុកទិន្នន័យ។ ការសាងសង់មជ្ឈមណ្ឌលការពារទិន្នន័យ (Disaster Recovery Data Center) នឹងជួយរក្សាទិន្នន័យនៅក្នុងបរិយាកាសដែលមានការការពារខ្ពស់។ ធនាគារមានទំនុកចិត្តចំពោះពេលអនាគត ជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងផលិតផល-សេវាកម្ម ដែលនឹងកាន់តែមានភាពល្អប្រសើរ។

## ខ- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១- ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

សម្ព័ន្ធធនាគារ ទទួលបានជោគជ័យនៅលើទីផ្សារអាស្រ័យដោយកត្តាពីរគឺៈ

- កំណើនសំពៀតឥណទាន ដោយសារតម្រូវការខ្ពស់នៅលើទីផ្សារលើផលិតផលឥណទានរបស់សម្ព័ន្ធធនាគារ ជាពិសេសសហគ្រាសធុនតូច និងមធ្យម។
- កំណើនប្រាក់បញ្ញើ-សន្សំ របស់សម្ព័ន្ធធនាគារ រួមជាមួយផលិតផល និងសេវាកម្មផ្សេងទៀត។

កត្តាទាំងពីរនេះត្រូវបានផ្សារភ្ជាប់ជាមួយនឹងការអភិវឌ្ឍឥតឈប់ឈរនៃប្រព័ន្ធឌីជីថលរបស់សម្ព័ន្ធធនាគារ ដែលផ្តល់ជូនអតិថិជននូវផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិត និងទាន់សម័យ។

សម្ព័ន្ធធនាគារ បាននិងកំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធចម្រុះឱ្យកាន់តែទូលំទូលាយសម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយនឹងការិយាល័យទាំង៣២១ តាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗទៅជាមជ្ឈមណ្ឌលដែលអាចធ្វើស្វ័យប្រតិបត្តិការដែលមានទីតាំងធនាគារស្វ័យប្រវត្តិចំនួន២០៦ ព្រមទាំងមាន **ម៉ាស៊ីនអេធីអឹមអេស៊ីលីដា** ចំនួន១.៤១៦ គ្រឿង **ម៉ាស៊ីនដាក់ប្រាក់បញ្ញើមានកាលកំណត់** ចំនួន២៦ គ្រឿង **ម៉ាស៊ីនបើកគណនី និងបោះពុម្ពប័ណ្ណអេធីអឹម** ចំនួន៩៦ គ្រឿង **ម៉ាស៊ីនទទួលកាបូបប្រាក់** ចំនួន១៧ គ្រឿង និង **ម៉ាស៊ីនឆូតកាត**ចំនួន៥.៥៥៣ គ្រឿង។ ចំណុចគួរជាទីមោទនភាពគឺសម្ព័ន្ធធនាគារ បានបោះពុម្ពប័ណ្ណ**អេធីអឹមអេស៊ីលីដា** ចំនួន ១,៨០ លានប័ណ្ណជូនដល់អតិថិជន។ ទន្ទឹមនឹងនេះ **អេស៊ីលីដាម៉ូបាល** បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំង ដែលចំនួននៃអ្នកចុះឈ្មោះប្រើប្រាស់បានកើនដល់ ៤,៩០ លាននាក់ នៅដំណាច់ខែធ្នូ ឆ្នាំ២០២៤នេះ ដែលអាចជួយឱ្យចរាចរសាច់ប្រាក់បានឆាប់រហ័សនៅក្នុងសេដ្ឋកិច្ច។

ការបង្កើនភាពងាយស្រួលដល់អតិថិជន និងពង្រឹងប្រព័ន្ធសុវត្ថិភាពអ៊ីនធើណែត គឺជាចំណុចដែលសម្ព័ន្ធធនាគារ ផ្តោតការយកចិត្តទុកដាក់បំផុត។ ដើម្បីសម្រេចនូវវឌ្ឍនភាពគោលដៅដ៏រឹងមាំទាំងនេះ សម្ព័ន្ធធនាគារ នឹងបន្តលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន តាមរយៈការវិនិយោគលើបច្ចេកវិទ្យាទំនើបចុងក្រោយ ពង្រឹងសមត្ថភាពធនធានមនុស្ស ព្រមទាំងពង្រីកនិងកែលម្អដំណើរការអាជីវកម្ម។ ជាយុទ្ធសាស្ត្រ សម្ព័ន្ធធនាគារកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ដែលអាចឱ្យដៃគូទាំងក្នុង និងក្រៅប្រទេសអាចភ្ជាប់ប្រព័ន្ធនេះដើម្បីបម្រើអតិថិជនទៅវិញទៅមក និងឆ្លងព្រំដែន។ ប្រព័ន្ធនេះមិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដោយផ្ទាល់ដល់អតិថិជនដ៏ឆ្លាតវៃរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដៃគូអាជីវកម្មរបស់ពួកគាត់ផងដែរ។ យើងខ្ញុំទទួលស្គាល់ថាអតិថិជន និងដៃគូអាជីវកម្មទាំងអស់គឺជាបណ្តាញតភ្ជាប់ដ៏មានសារសំខាន់សម្រាប់ពង្រីកសេវាកម្មរបស់សម្ព័ន្ធធនាគារ និងរីកចម្រើនជាមួយគ្នា។

**អេស៊ីលីដាម៉ូបាល** ត្រូវបានកែលម្អយ៉ាងទូលំទូលាយ និងផ្លាស់ប្តូររូបរាងថ្មី កាន់តែទំនើប ងាយស្រួល និងមានសុវត្ថិភាពខ្ពស់ ជាមួយនឹងមុខងារពិសេសៗជាច្រើន។ ឥឡូវនេះ អតិថិជនទាំងអស់អាចធ្វើប្រតិបត្តិការប្រាក់បញ្ញើ-សន្សំ (សំចៃ ចរន្ត និងមានកាលកំណត់) តាមរយៈ **អេស៊ីលីដាម៉ូបាល** បានភ្លាមៗ ថែមទាំងទទួលបានការប្រាក់ខ្ពស់ទៀតផង។

**ខេអេចឃ្យូអរកូដ (KHQR Code)** ផ្តល់នូវភាពងាយស្រួលជាងមុនជូនដល់អ្នកប្រើប្រាស់ក្នុងការធ្វើប្រតិបត្តិការទូទាត់ថ្លៃទំនិញ និងសេវាកម្មផ្សេងៗប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងទំនុកចិត្តខ្ពស់ រវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានផ្តល់សេវាទូទាត់សងប្រាក់ ដែលជាសមាជិករបស់កម្មវិធីបាគង (**Bakong App**)។

ឥឡូវនេះ ជាមួយ**អេស៊ីលីដាម៉ូបាល** ពិតជាងាយស្រួល ដោយលោកអ្នកអាចទូទាត់ផ្សេងៗ តាម QR Code (Scan QR) បានគ្រប់ទីកន្លែង នៅទូទាំងប្រទេសថៃ វៀតណាម និងឡាវ ដោយឥតគិតថ្លៃសេវា។ នេះជាភាពជោគជ័យថ្មីមួយទៀតរបស់ប្រព័ន្ធបាគង និងធនាគារ អេស៊ីលីដា ដែលជាសមាជិករបស់បាគង។

## ២- ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ប្រតិបត្តិការក្នុងវិស័យសេវាកម្ម ដែលការឡើងចុះនៃថ្លៃវត្ថុធាតុដើមមិនអាចអនុវត្តបានចំពោះធនាគារឡើយ។

## ៣- ការវិភាគលើពន្ធ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ស្ថិតនៅក្រោមច្បាប់ស្តីពីពន្ធដារនៃប្រទេសនីមួយៗ ដូច្នេះធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធមានកាតព្វកិច្ចបង់ពន្ធតាមការកំណត់របស់អាជ្ញាធរពន្ធដារនីមួយៗ។

ការបង់ពន្ធជូនអគ្គនាយកដ្ឋានពន្ធដារមិនត្រឹមតែជាកាតព្វកិច្ច និងការទទួលបានវិញ្ញាបនបត្រអនុលោមភាពសារពើពន្ធប្រភេទ **"មាស"** ពីអគ្គនាយកដ្ឋានពន្ធដារសម្រាប់ឆ្នាំជាប់ពន្ធ**២០២៤** ដល់**២០២៥** ប៉ុណ្ណោះទេ ប៉ុន្តែជាការចូលរួមចំណែកក្នុងសង្គម និងកំណើនសេដ្ឋកិច្ចផងដែរ។

ចំណូលពន្ធគឺជាប្រភពចំណូលដ៏សំខាន់បំផុតសម្រាប់ប្រទេស។ រដ្ឋាភិបាលប្រមូលពន្ធកាន់តែច្រើន ការចូលរួមវិភាគទានកាន់តែច្រើនដល់ការអភិវឌ្ឍប្រទេស។ ធនាគារ អេស៊ីលីដា ភីអិលស៊ី មានមោទនភាពដែលអាចចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាយើង។

## ៤- ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

សម្ព័ន្ធធនាគារ មិនមានធាតុ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលខុសពីធម្មតាជាសារវន្តនោះទេ។ ទោះជាយ៉ាងណាក៏ដោយ សេដ្ឋកិច្ចពិភពលោកបានជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន រួមជាមួយនឹងការកើនឡើងអតិផរណា អត្រាការប្រាក់ខ្ពស់ និងភាពតានតឹងភូមិសាស្ត្រនយោបាយ អាចជះឥទ្ធិពលដល់សមត្ថភាពសងត្រលប់មកវិញរបស់អតិថិជន ដែលគុណភាពឥណទានរបស់សម្ព័ន្ធធនាគារ អាចរងផលប៉ះពាល់បន្តិចបន្តួច។

# គ- ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ដើម្បីចូលរួមគាំទ្រការរីកលូតលាស់អាជីវកម្មរបស់អតិថិជន សម្ព័ន្ធធនាគារ បានផ្តល់អត្រាការប្រាក់មានភាពប្រកួតប្រជែងខ្លាំងចំពោះការស្នើសុំឥណទានថ្មីគ្រប់ប្រភេទ និងដោយកាន់តែមានភាពងាយស្រួល អតិថិជនទាំងអស់អាចដាក់សំណើសុំឥណទានតាមរយៈ **អេស៊ីលីដាម៉ូបាល**។ ជាលទ្ធផល សមតុល្យឥណទានដុលសរុបនៅដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៤ មានការកើនឡើងចំនួន ១.៤៥៨,៩៥ ប៊ីលានរៀល ឬ ៥,៣៦% ធៀបនឹងដំណាច់ត្រីមាសទី៤ ឆ្នាំ២០២៣។

## ឃ- ផលប៉ះពាល់នៃការប្តូររូបិយប័ណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

នៅត្រីមាសទី៤ ឆ្នាំ២០២៤ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានចន្លោះពី ៤.០២៥ ទៅ ៤.០៦៦ រៀល ក្នុងមួយដុល្លារអាមេរិក បានឆ្លុះបញ្ចាំងការឡើងថ្លៃគួរឱ្យកត់សម្គាល់ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (ចន្លោះពី ៤.១០៧ ទៅ ៤.១៣៣ រៀល ក្នុងមួយដុល្លារអាមេរិក)។ ការឡើងថ្លៃរបស់ប្រាក់រៀលនេះ មួយផ្នែកមកពីការបន្តងើបឡើងវិញនៃសកម្មភាពសេដ្ឋកិច្ច តួយ៉ាងវិស័យទេសចរណ៍ វិស័យកាត់ដេរ ផលិតផលមិនមែនសម្លៀកបំពាក់ និងវិស័យសេវាកម្មផ្សេងៗ ដែលនាំឱ្យតម្រូវការប្រាក់រៀលកាន់តែកើនឡើង។ ប្រមើលទៅខាងមុខ តម្លៃប្រាក់រៀលត្រូវបានរំពឹងថានឹងនៅតែមានស្ថិរភាពដែលជំរុញដោយតម្រូវការទីផ្សារ និងនិន្នាការផ្គត់ផ្គង់ ការងើបឡើងវិញបន្តិចម្តងៗនៃសកម្មភាពសេដ្ឋកិច្ច និងទំនុកចិត្តរបស់សាធារណជនលើប្រាក់រៀល ជាពិសេស ការគាំទ្រពីធនាគារជាតិ នៃ កម្ពុជា ដោយបានតាមដានយ៉ាងដិតដល់នូវតម្លៃរបស់ប្រាក់រៀល ចាត់ចែងរក្សាអត្រាប្តូរប្រាក់រៀល ដើម្បីរក្សាស្ថិរភាពតម្លៃរូបិយវត្ថុជាតិ និងសមភាពអំណាចទិញ និងបន្តអនុវត្តគោលនយោបាយរូបិយវត្ថុជាបន្តបន្ទាប់។

ចំពោះធនាគារ អេស៊ីលីដា បានវាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងស្ថានភាពរូបិយប័ណ្ណចំហជាប្រចាំថ្ងៃ ដោយប្រតិបត្តិបានយ៉ាងត្រឹមត្រូវ និងគ្រប់គ្រាន់ អនុវត្តតាមបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា និងគោលនយោបាយហានិភ័យផ្ទៃក្នុងរបស់ខ្លួន ដូច្នេះមិនមានផលប៉ះពាល់ជាសារវន្តដល់ធនាគារឡើយ។

ធនាគារកណ្តាលសហរដ្ឋអាមេរិកបានកាត់បន្ថយអត្រាការប្រាក់ចំនួន ០,២៥% មកនៅត្រឹមចន្លោះ ៤,២៥% ទៅ ៤,៥០% ក្នុងខែធ្នូ ឆ្នាំ២០២៤ ដែលជាការកាត់បន្ថយអត្រាការប្រាក់លើកទីបី សម្រាប់ឆ្នាំ២០២៤។ ទោះជាយ៉ាងណាក៏ដោយ មិនមានផលប៉ះពាល់ជាសារវន្តដល់ធនាគារ អេស៊ីលីដា ឡើយ ដោយហេតុថាធនាគារបានដំណើរការស្ទើរតែទាំងស្រុង ដោយការផ្គូរផ្គងផ្នែកទាំងពីរនៃទ្រព្យសកម្ម និងបំណុលអកម្មលើមូលដ្ឋានអត្រាការប្រាក់ថេរ និងត្រួតពិនិត្យជាប្រចាំ ដើម្បីចាត់វិធានការសមស្របនិងទាន់ពេលវេលា ដែលអាចជៀសវាងផលប៉ះពាល់ដល់អាជីវកម្មរបស់ខ្លួន។

ដោយឡែកចំពោះប្រតិបត្តិការជួញដូរនានា ដែលមានទម្រង់ជាទំនិញ (Commodities) ធនាគារមិនមានផ្តល់សេវាបែបនោះទេ។ ដូច្នេះមិនមានផលប៉ះពាល់ដល់ធនាគារឡើយ។

## ង- ផលប៉ះពាល់នៃអតិផរណា

អត្រាអតិផរណាប្រចាំឆ្នាំជាមធ្យមក្នុងឆ្នាំ២០២៤ នៅក្នុងទិន្នន័យស្ថិតិរូបិយវត្ថុ និងហិរញ្ញវត្ថុ ចេញដោយធនាគារជាតិ នៃ កម្ពុជា នៅខែមករា ឆ្នាំ២០២៥ ស្ថិតនៅក្នុងរង្វង់ ៣,០៥%។ មានការបន្តងើបឡើងវិញនៃសកម្មភាពចាយវាយ និងប្រើប្រាស់ក្នុងស្រុក ស្របពេលដែលថ្លៃទំនិញអន្តរជាតិនៅបន្តរក្សាបានស្ថិរភាព។ ចំពោះប្រតិបត្តិការរបស់ធនាគារ គឺមិនត្រូវបានផ្សារភ្ជាប់ដោយផ្ទាល់ទៅនឹងកម្រិតអតិផរណានោះទេ។ ជាលទ្ធផល មិនមានផលប៉ះពាល់ជាសារវ័ន្តលើប្រតិបត្តិការធនាគារឡើយ។

## ច- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រាជរដ្ឋាភិបាល

- <u>គោលនយោបាយសេដ្ឋកិច្ច៖</u>

ធនាគារជាតិ នៃ កម្ពុជា បានផ្តល់ជារបាយការណ៍ថា សកម្មភាពសេដ្ឋកិច្ចនៅកម្ពុជាបានបន្តងើបឡើង ដែលគាំទ្រជាចម្បងដោយកំណើនកម្មន្តសាលកាត់ដេរ ទេសចរណ៍ កសិកម្ម និងសំណង់៖

១. វិស័យកម្មន្តសាលត្រូវបានរំពឹងថាមានកំណើន ៧,៣% ដែលជំរុញដោយកំណើនផលិតផលកម្មន្តសាលសម្រាប់បម្រើការនាំចេញ ៧,៧% និងផលិតផលកម្មន្តសាលសម្រាប់បម្រើទីផ្សារក្នុងស្រុក ៦,៤%។

២. វិស័យទេសចរណ៍បន្តទទួលបានកំណើនល្អ ដោយចំនួនភ្ញៀវអន្តរជាតិបានកើនឡើងដល់ ៣,១ លាននាក់ និងទេសចរក្នុងស្រុកកើនដល់ ៩,៧ លាននាក់ ដែលគាំទ្រដោយភាពប្រសើរឡើងនៃសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងកំណើនជើងហោះហើរត្រង់ជាមួយនឹងប្រទេសនានា។

៣. វិស័យកសិកម្ម ទិន្នផលស្រូវរដូវប្រាំង កៅស៊ូ និងអនុវិស័យជលផល បានកើនឡើង ២១% ១% និង ៥,១% រៀងគ្នា។

៤. វិស័យសំណង់បានងើបឡើងក្នុងកម្រិតទាប ដែលគាំទ្រដោយគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈ ខណៈដែលវិស័យអចលនទ្រព្យបន្តមានភាពទន់ខ្សោយ ដោយតម្លៃ និងការលក់លំនៅឋាន និងខុនដូបានធ្លាក់ចុះ។
៥. សម្រាប់វិស័យក្រៅប្រទេស សមតុល្យជញ្ជីងទូទាត់កម្ពុជាត្រូវបានប៉ាន់ស្មានថាមានអតិរេក ១៤៧,៩ លានដុល្លារអាមេរិក ដែលគាំទ្រជាចម្បងដោយការកើនឡើងនៃចំណូលពីសេវាធ្វើដំណើរ និងវិនិយោគផ្ទាល់បរទេស។ ទុនបម្រុងអន្តរជាតិបន្តស្ថិតក្នុងកម្រិតខ្ពស់ ២០ ប៊ីលានដុល្លារអាមេរិក ដែលស្មើនឹងប្រមាណ ៧ខែ នៃការនាំចូលទំនិញ និងសេវាសម្រាប់គ្រាបន្ទាប់ ខ្ពស់ជាងកម្រិតអប្បបរមាសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍គួរមាន (៣ខែ)។

ស្របគ្នានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានព្យាករផងដែរថា សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងកើនឡើងក្នុងអត្រា ៦,៣% ក្នុងឆ្នាំ២០២៥ នេះបើយោងតាមរបាយការណ៍ថវិកាសង្ខេបសម្រាប់ឆ្នាំសារពើពន្ធ២០២៥ ដែលចេញផ្សាយដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF)។ យោងតាមការវាយតម្លៃនៃក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមរបស់រាជរដ្ឋាភិបាល កំណើននេះត្រូវបានគេរំពឹងថានឹងធ្វើឱ្យតម្លៃផលិតផលក្នុងស្រុកសរុប (GDP) បច្ចុប្បន្នកើនឡើងដល់ប្រហែល ២០៩.១៦៣ ពាន់លានរៀល ស្មើនឹងប្រមាណ ៥១,៣៩ ពាន់លានដុល្លារអាមេរិក។ ទន្ទឹមនឹងនេះ GDP សម្រាប់មនុស្សម្នាក់ត្រូវបានគេរំពឹងថានឹងឈានដល់ ២.៩២៤ ដុល្លារអាមេរិក។ តាមការព្យាករកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០២៥ នឹងត្រូវបានគាំទ្រជាចម្បងដោយវិស័យសំខាន់ៗដូចជា ឧស្សាហកម្ម សេវាកម្ម និងកសិកម្ម។ [(១), (២)]

យោងតាមព័ត៌មានដែលបានចុះផ្សាយរបស់ស្ថាប័នល្បីល្បាញ មួយចំនួននៅបន្តព្យាករ GDP ឆ្នាំ២០២៤ របស់កម្ពុជាផងដែរ។ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងកើនឡើងក្នុងអត្រា ៥,៨% ក្នុងឆ្នាំ២០២៤ និង ៦% ក្នុងឆ្នាំ២០២៥។ វាបានកែសម្រួលការព្យាករអតិផរណាមុនរបស់ខ្លួនសម្រាប់ឆ្នាំ២០២៤ ពី ២% ទៅ ០,៥% ដែលឆ្លុះបញ្ចាំងពីការកើនឡើងយឺតនៃតម្លៃម្ហូបអាហារ និងការធ្លាក់ចុះនៃតម្លៃប្រេងឥន្ធនៈនៅក្នុងឆមាសទីមួយនៃឆ្នាំ២០២៤ នេះបើយោងតាមទស្សនវិស័យអភិវឌ្ឍន៍អាស៊ី (ADO) ខែកញ្ញា ឆ្នាំ២០២៤។ មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើង ៥,៥% ក្នុងឆ្នាំ២០២៤ និង ៥,៨% សម្រាប់ឆ្នាំ២០២៥ ដូចក្នុងរបាយការណ៍ទស្សនវិស័យសេដ្ឋកិច្ចក្នុងតំបន់សម្រាប់អាស៊ី និងប៉ាស៊ីហ្វិក ខែតុលា ឆ្នាំ២០២៤។ ធនាគារពិភពលោក (WB) កំណើន GDP ពិតប្រាកដរបស់កម្ពុជាត្រូវបានព្យាករថានឹងមានភាពប្រសើរឡើងបន្តិច ដោយឈានដល់ ៥,៥% នៅឆ្នាំ២០២៥ និង ២០២៦។ ទោះបីជាតម្រូវការក្នុងស្រុកត្រូវបានគេរំពឹងថានឹងមានភាពប្រសើរឡើងបន្ថែមទៀតក្នុងរយៈពេលពីរឆ្នាំខាងមុខ ដែលត្រូវបានគាំទ្រដោយទីផ្សារការងារដែលមានភាពប្រសើរឡើង និងការរំពឹងទុកនៃអតិផរណាល្មក៏ដោយ ក៏ការស្ទុះងើបឡើងវិញនៅតែមិនពេញលេញ។ នេះគឺដោយសារតែការស្ទុះងើបឡើងវិញនៃការប្រើប្រាស់ក្នុងស្រុកដែលមានប្រហែល ២ ភាគ ៣ នៃផលិតផលក្នុងស្រុកសរុប នឹងត្រូវបានបង្អាក់ដោយកំណើនឥណទានក្នុងស្រុកដែលធ្លាក់ចុះដែលបណ្តាលមកពីការធ្លាក់ចុះរយៈពេលយូរនៅក្នុងវិស័យសំណង់ និងអចលនទ្រព្យ។ លើសពីនេះ ឥទ្ធិពលទ្រព្យសម្បត្តិអវិជ្ជមាននៃការធ្លាក់ចុះតម្លៃផ្ទះ និងជាពិសេសបំណុលគ្រួសារខ្ពស់ ជាមួយនឹងការទូទាត់សេវាបំណុលជិត ៥០% នៃប្រាក់ចំណូលទំនងជានឹងរារាំងការប្រើប្រាស់បន្តទៅមុខ។ [(៣), (៤), (៥)]

- <u>**គោលនយោបាយសារពើពន្ធ**</u>

សម្រាប់ឆ្នាំ២០២៤ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញនូវវិធានការសំខាន់ៗ និងជាយុទ្ធសាស្ត្រសំខាន់ៗដូចតទៅ៖
(១) បន្តពង្រឹងការផ្សព្វផ្សាយ និងការអនុវត្តប្រកបដោយការយកចិត្តទុកដាក់នូវវិធានការលើកទឹកចិត្ត និងសម្រួលផ្នែកពន្ធដារជូនវិស័យឯកជននាពេលកន្លងមក និងក្នុងក្របខ័ណ្ឌវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជនលើកទី១៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**សម្តេចធិបតី នាយករដ្ឋមន្ត្រី** កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣។
(២) បន្តរៀបចំ និង/ឬធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្ត (ប្រកាស សេចក្តីណែនាំ និង/ឬសេចក្តីជូនដំណឹង) ក្នុងការអនុវត្តនូវវិធានការលើកទឹកចិត្ត និងការសម្រួលផ្នែកពន្ធដារ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ ព្រមទាំងបន្តពង្រឹងការអនុវត្តប្រកបដោយការយកចិត្តទុកដាក់តាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចធិបតី នាយករដ្ឋមន្ត្រី** ដាក់ចេញកន្លងមកក្នុងការពង្រឹងគុណភាពនៃការផ្តល់សេវា និងប្រសិទ្ធភាពការងារ។

(៣) បន្តពង្រឹងការយកចិត្តទុកដាក់ខ្ពស់លើគុណភាពនៃការផ្តល់សេវា និងលើកកម្ពស់ប្រសិទ្ធភាពការងាររបស់ខ្លួន ស្របតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចធិបតី នាយករដ្ឋមន្ត្រី** និងដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារ ៤ ប្រការ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

(៤) បន្តជំរុញ និងបង្កើនល្បឿននៃការធ្វើបរិវត្តកម្មរដ្ឋបាលសារពើពន្ធ និងបន្តធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងកម្មវិធីប្រកបដោយស្មារតីបុរេសកម្ម តាមរយៈការអភិវឌ្ឍនិងធ្វើបច្ចុប្បន្នភាព និងអភិវឌ្ឍន៍ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ និងពង្រឹងសមត្ថភាពមុខងារវិភាគទិន្នន័យបន្ថែមទៀត ដើម្បីបន្តជំរុញបង្កើនកម្រិតអនុលោមភាពសារពើពន្ធ ដោយធ្វើយ៉ាងណាឱ្យមានភាពងាយស្រួលក្នុងការបំពេញកាតព្វកិច្ចពន្ធដារ ប៉ុន្តែពិបាកក្នុងការគេចវេះ តាមរយៈការបន្តអភិវឌ្ឍបន្ថែមនូវមុខងារមួយចំនួន តាមធាតុចូលដែលទទួលបានពីអ្នកប្រើប្រាស់គ្រប់មជ្ឈដ្ឋាន ដើម្បីឱ្យកាន់តែមានភាពគ្រប់ជ្រុងជ្រោយ និងងាយស្រួលក្នុងការអនុវត្ត។

(៥) បន្តរៀបចំការបណ្តុះបណ្តាលជូនមន្ត្រី និងផ្សព្វផ្សាយឱ្យបានទូលំទូលាយជូនអ្នកជាប់ពន្ធ និងសាធារណជនអំពី "សៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការធ្វើសវនកម្មពន្ធដារសម្រាប់មន្ត្រីពន្ធដារ និងអ្នកជាប់ពន្ធ" និង "សៀវភៅណែនាំស្តីពីការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌលើបទប្បញ្ញត្តិស្តីពីពន្ធដារ"។

(៦) បន្តផ្សព្វផ្សាយ និងពង្រឹងការអនុវត្តនូវ "កម្មវិធីរដ្ឋបាលអេឡិចត្រូនិកពន្ធដារ GDT e-Administration" និង "កម្មវិធីត្រួតពិនិត្យ និងតាមដានឯកសារ GDT Check and Track" ដែលនឹងក្លាយជាឧបករណ៍ទំនើប ដើម្បីគាំទ្ររាល់ការផ្តល់សេវាអ្នកជាប់ពន្ធ ដែលផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធ និងសាធារណជនក្នុងការដាក់និងតាមដានលិខិតរដ្ឋបាលនានា។

(៧) បន្តផ្សព្វផ្សាយ និងពង្រឹងការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ ពន្ធលើថ្លៃឈ្នួលអចលនទ្រព្យ និងពន្ធលើមធ្យោបាយដឹកជញ្ជូនសម្រាប់ឆ្នាំ២០២៤។

(៨) បន្តពង្រឹងតម្លាភាព និងគណនេយ្យភាពនៃការបង់ពន្ធរបស់សហគ្រាសក្នុងវិស័យផលិតស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា ដោយបន្តពង្រឹងអនុវត្តយន្តការបំពាក់កាមេរ៉ាសុវត្ថិភាពនៅតាមរោងចក្រផលិតស្រាបៀរ និងភេសជ្ជៈគ្មានជាតិសុរា ឱ្យបានរួចរាល់គ្រប់សហគ្រាស ការចុះត្រួតពិនិត្យឧបករណ៍វាស់ចំណុះ (Flowmeter) ក្នុងខ្សែច្រវាក់ផលិតកម្មដល់ទីតាំង ដោយថ្នាក់ដឹកនាំរបស់អគ្គនាយកដ្ឋានពន្ធដារ និងការបន្តពង្រឹងការអនុវត្តការងារ និងវត្តមានរបស់មន្ត្រីប្រចាំការ។

(៩) បន្តពង្រឹងការងារចុះបញ្ជីពន្ធដារ និងធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស និងបន្តកិច្ចសហការជាមួយក្រសួងពាណិជ្ជកម្ម និងស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមកែលម្អ និងជំរុញការងារចុះបញ្ជីសហគ្រាសតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (CamDX) ឱ្យកាន់តែមានប្រសិទ្ធភាព និងមានភាពគ្រប់ជ្រុងជ្រោយ តាមរយៈការពិនិត្យ និងស្វែងរកដំណោះស្រាយចំពោះបញ្ហាប្រឈមនានា។

(១០) បន្តពង្រឹងកិច្ចសហការជាមួយវិស័យឯកជន ជាពិសេសក្នុងក្របខ័ណ្ឌនៃកិច្ចសហការជាមួយវិស័យឯកជន និងសភាពាណិជ្ជកម្មនានា។

(១១) បន្តជំរុញលើការងាររៀបចំចរចា និងពង្រីកវិសាលភាពនៃកិច្ចព្រមព្រៀងស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា (DTA) ជាមួយបណ្តាប្រទេសនានា។

(១២) បន្តរៀបចំលិខិតបទដ្ឋានគតិយុត្ត និងផែនការសកម្មភាព ដើម្បីគាំទ្រការអនុវត្តវិធានការនានាពាក់ព័ន្ធនឹងពន្ធដារ ដូចមានកំណត់នៅក្នុងយុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ២០២៣-២០២៨។

(១៣) បន្តផ្សព្វផ្សាយច្បាប់ស្តីពីសារពើពន្ធ ជូនដល់អ្នកជាប់ពន្ធ សាធារណជន ព្រមទាំងក្រុមការងារវិស័យឯកជន និងអង្គការសមាគមនានាតាមគ្រប់រូបភាព ព្រមទាំងបន្តរៀបចំធ្វើបច្ចុប្បន្នភាពលិខិតបទដ្ឋានគតិយុត្តនានាស្តីពីពន្ធដារឱ្យស្របតាមច្បាប់ស្តីពីសារពើពន្ធ។

(១៤) បន្តការងារកែទម្រង់ធនធានមនុស្ស ដោយជំរុញ និងខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងត្រូវមានភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយផ្អែកលើទិដ្ឋភាពច្បាប់ក្នុងការផ្តល់សេវាអ្នកជាប់ពន្ធ និងការគ្រប់គ្រងប្រមូលចំណូលពន្ធ។

(១៥) បន្តពង្រឹងការផ្តល់សេវាពិគ្រោះយោបល់ និងការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តស្តីពីពន្ធដារតាមគ្រប់រូបភាព ជាពិសេសការផ្តល់សេវាពិគ្រោះយោបល់តាមរយៈទូរស័ព្ទ (Call Center-1277) និងការរៀបចំកម្មវិធី "ពន្ធដារកម្ពុជា" (GDT Facebook Live) ដើម្បីពន្យល់ និងដោះស្រាយការលំបាក និងចម្ងល់នានារបស់ប្រជាពលរដ្ឋ។

(១៦) បន្តពង្រឹងប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពរបស់ក្រុមការងារអ្នកនាំពាក្យ និងប្រតិកម្មរហ័សនៃអគ្គនាយកដ្ឋានពន្ធដារ និងការចូលរួមដោយសកម្មជាមួយក្រុមការងារតាមដានសាធារណមតិ និងប្រតិកម្មរហ័សរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បី

តាមដានបញ្ហាសាធារណមតិ និងផ្សព្វផ្សាយឱ្យសាធារណជនបានជ្រួតជ្រាបកាន់តែច្បាស់ពីការខិតខំប្រឹងប្រែង កសាងសមិទ្ធផលយ៉ាងសន្ធឹកសន្ធាប់ ដែលរាជរដ្ឋាភិបាលបានសម្រេចជូនជាតិមាតុភូមិ។ [៦]

សរុបរយៈពេល ៩ខែ ឆ្នាំ២០២៤ ចំណូលពន្ធ-អាករ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារ មានចំនួន ១០.៦៨៩,១៨ ប៊ីលានរៀល (ប្រមាណជា ២.៦៣៩,៣០ លានដុល្លារអាមេរិក) ស្មើនឹង ៦៣,៣៨% នៃផែនការច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៤។ ចំពោះលទ្ធផលនៃការគ្រប់គ្រងប្រមូលចំណូលពន្ធបានបង្ហាញថា ក្នុងខែកញ្ញា ឆ្នាំ២០២៤ ចំណូលពន្ធ-អាករគ្រប់ប្រភេទ ដែលអគ្គនាយកដ្ឋានពន្ធដារប្រមូលបានជាក់ស្តែងតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញរបស់អគ្គនាយកដ្ឋានពន្ធដារមានចំនួន ៩៨៩,៧៣ ប៊ីលានរៀល។ [៧]

- **<u>គោលនយោបាយរូបិយវត្ថុ៖</u>**

សម្រាប់ឆ្នាំ២០២៤ ធនាគារជាតិ នៃ កម្ពុជា បានកំណត់អនុវត្តន៍គោលនយោបាយរូបិយវត្ថុចំនួន៦ ដើម្បីគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការស្តារកំណើនសេដ្ឋកិច្ចជាតិ រួមមាន៖

(១) គ្រប់គ្រងការផ្គត់ផ្គង់រូបិយវត្ថុឱ្យស្ថិតក្នុងកម្រិតសមស្រប
(២) រក្សាស្ថិរភាពអត្រាប្តូរប្រាក់ ដោយតាមដាន និងធ្វើអន្តរាគមន៍តាមការចាំបាច់ ដើម្បីរួមចំណែករក្សាស្ថិរភាពថ្លៃ និងជំនឿទុកចិត្តរបស់សាធារណជនលើរូបិយវត្ថុជាតិ
(៣) លើកកម្ពស់ការប្រើប្រាស់ និងចំណេះដឹងពីប្រាក់រៀល
(៤) កែលម្អ និងពង្រឹងប្រសិទ្ធភាពឧបករណ៍នយោបាយរូបិយវត្ថុដែលមាន និងអភិវឌ្ឍឧបករណ៍នយោបាយរូបិយវត្ថុថ្មីៗ
(៥) ជំរុញការអភិវឌ្ឍទីផ្សារអន្តរធនាគារ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពនយោបាយរូបិយវត្ថុ និង
(៦) លើកកម្ពស់ការយល់ដឹងរបស់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុស្តីពីក្របខ័ណ្ឌ និងឧបករណ៍នយោបាយរូបិយវត្ថុរបស់ធនាគារជាតិ នៃ កម្ពុជា។ [១]

ឯកសារយោងៈ
(១) https://www.nbc.gov.kh/download_files/publication/annual_rep_kh/Semi_Final_Report_2024.pdf
(២) https://www.khmertimeskh.com/501625074/cambodias-economy-projected-to-grow-at-6-3-in-2025/
(៣) https://www.adb.org/news/adb-maintains-cambodia-growth-forecast-2024-2025
(៤) https://www.imf.org/en/Publications/REO/APAC/Issues/2024/10/31/regional-economic-outlook-for-asia-and-pacific-october-2024
(៥) https://documents1.worldbank.org/curated/en/099120924052010564/pdf/P506814195fb5d00e198eb150a46c722a27.pdf
(៦) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/2e8790c9-020b-453f-b743-4b1bad3729a8
(៧) https://www.tax.gov.kh/u6rhf7ogbi6/gdtstream/50de5995-7266-4718-a593-d168123a178b

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ**

ថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៥

បានអាន និងឯកភាព

ហត្ថលេខា

**ឆាយ សឿន**

**ប្រធានក្រុមប្រឹក្សាភិបាល**

ការិយាល័យកណ្ដាល ៖ អគារលេខ៦១ មហាវិថីព្រះមុនីវង្ស
សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩ | ទូរសារ ៖ ០២៣ ៤៣០ ៥៥៥
acledabank@acledabank.com.kh | www.acledabank.com.kh
ប្រអប់សំបុត្រលេខ ៖ ១១៤៩ | SWIFT Code ៖ ACLBKHPP

ការិយាល័យទំនាក់ទំនងអតិថិជន (បម្រើ ២៤ម៉ោង)
ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
inquiry@acledabank.com.kh